# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥០ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពគណៈកម្មាធិការតម្រែតម្រង់ទិស សម្រាប់ផ្តល់នូវការណែនាំពីគោលនយោបាយ និងយុទ្ធសាស្ត្រនានា ដល់ការអនុវត្តគម្រោងទ្រទ្រង់ជីវភាពប្រជាជនប្រកបដោយនិរន្តរភាពនៅតាមបណ្តាខេត្ត ជុំវិញបឹងទន្លេសាប ក្នុងក្របខ័ណ្ឌជំនួយឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/១០៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ-បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការរៀបចំសមាសភាព រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និង ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ
- បានឃើញកិច្ចព្រមព្រៀងផ្តល់ជំនួយឥតសំណងលេខ 0034-CAM(SF) ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ២០០៦ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីគម្រោងទ្រទ្រង់ជីវភាពប្រជាជនប្រកបដោយនិរន្តរភាពនៅតាមបណ្តាខេត្តជុំវិញបឹងទន្លេសាប
- យោងសេចក្តីសម្រេចលេខ ១០ សសរ ចុះថ្ងៃទី ០៤ មេសា ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

កែសម្រួលសមាសភាពគណៈកម្មាធិការតម្រែតម្រង់ទិសសម្រាប់ផ្តល់ការណែនាំពីគោលនយោបាយ និងយុទ្ធសាស្ត្រនានា ដល់ការអនុវត្តគម្រោងជំនួយឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ ០០៣៤ CAM(SF) ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **វង្ស ទិវៈ** | អគ្គលេខាធិការ នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | ប្រធាន |
| ២- ឯកឧត្តម **លេខ ទី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងជាប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- ឯកឧត្តម **ណៅ ធួក** | ប្រធានរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៤- ឯកឧត្តម បណ្ឌិត **ចាន់ ដារ៉ុង** | អគ្គនាយកបច្ចេកទេស នៃក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៥- ឯកឧត្តម **សុខ ស៊ីឡូ** | អគ្គលេខាធិការរង នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | សមាជិក |
| ៦- ឯកឧត្តម **គល់ វឌ្ឍនា** | អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | សមាជិក |
| ៧- លោក **តឹកអ៊ែត សំរេច** | ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨- លោកបណ្ឌិត **នៅ ឆោនន័រ** | អនុប្រធាននាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន | សមាជិក |
| ៩- លោកស្រី **ជុត លាវទ៉ាន់នី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសមភាពយេនឌ័រ និងអភិវឌ្ឍសេដ្ឋកិច្ច នៃក្រសួងកិច្ចការនារី | សមាជិក |
| ១០- លោក **រស់ ចរម** | អនុប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១- លោក **ជូ ម៉ិនហៀង** | អនុប្រធាននាយកដ្ឋានកសិកម្មនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ | លេខាធិការ |

**ប្រការ២.-**

តួនាទី និង ភារកិច្ច

***គណៈកម្មាធិការ***

- ដឹកនាំ និងសម្របសម្រួលការអនុវត្តគម្រោងទ្រទ្រង់ជីវភាពប្រជាជនប្រកបដោយនិរន្តរភាពនៅតាមបណ្តាខេត្តជុំវិញបឹងទន្លេសាបតាមខ្លឹមសារនៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ីស្តីពីជំនួយឥតសំណងលេខ ០០៣៤ CAM(SF) ចុះថ្ងៃទី០៩ ខែ មិនា ឆ្នាំ២០០៦ ។

- ផ្តល់គោលនយោបាយ និងយុទ្ធសាស្ត្រផ្សេងៗដល់ភ្នាក់ងារប្រតិបត្តិគម្រោងទាំងអស់ ដែលពាក់ព័ន្ធនឹងគម្រោងទ្រទ្រង់ជីវភាពប្រជាជនប្រកបដោយនិរន្តរភាពនៅតាមបណ្តាខេត្តជុំវិញបឹងទន្លេសាប
- ជំរុញការអនុវត្តគម្រោងនានា ឱ្យទទួលបានលទ្ធផលតាមផែនការសកម្មភាពការងារ
- ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង
- សម្របសម្រួល និងដោះស្រាយបញ្ហាទាំងឡាយដែលអាចកើតមានឡើងក្នុងការអនុវត្តគម្រោង និងវិវាទដែលពាក់ព័ន្ធនឹងតួនាទីរបស់សាមីក្រសួងនិមួយៗក្នុងក្របខណ្ឌគម្រោង ក្នុងករណីចាំបាច់ត្រូវលើកសំណើជូនរាជរដ្ឋាភិបាល
- ដើរតួនាទីជាអ្នកគាំទ្រ និងសហការក្នុងការអនុវត្តគម្រោងឱ្យមានប្រសិទ្ធភាពតាមគ្រប់មធ្យោបាយ ។

***ប្រធាន***

- ជំរុញការអនុវត្តតួនាទី និងភារកិច្ចខាងលើឱ្យបានទទួលលទ្ធផលល្អប្រសើរ
- ធ្វើជាអធិបតីភាពក្នុងអង្គប្រជុំរបស់គណៈកម្មាធិការ
- កោះប្រជុំសាមញ្ញ ឬ ក្នុងករណីចាំបាច់ប្រជុំវិសាមញ្ញ របស់គណៈកម្មាធិការ
- ទទួលបន្ទុកទំនាក់ទំនងជាមួយភាគីបរទេស ដែលពាក់ព័ន្ធនឹងគម្រោងនេះ
- ជំរុញឱ្យមានទំនាក់ទំនងល្អរវាងគណៈកម្មាធិការតម្រែតម្រង់ទិសគម្រោង និងទីស្តីការគណៈរដ្ឋមន្ត្រី
- មានសិទ្ធិអញ្ជើញប្រធានក្រុមសម្របសម្រួលគម្រោងថ្នាក់ខេត្តមកប្រជុំ និង ធ្វើបទបង្ហាញពីលទ្ធផលការងារជូនគណៈកម្មាធិការ

***អនុប្រធាន***

- ត្រូវបំពេញរាល់កិច្ចការដែលប្រធានប្រគល់ឱ្យ
- ទទួលខុសត្រូវជាទូទៅលើការងាររបស់គណៈកម្មាធិការ ក្នុងករណីប្រធានអវត្តមាន
- អនុវត្តន៍តួនាទី និងភារកិច្ចដូចមានចែងក្នុងតួនាទី និង ភារកិច្ចរបស់សមាជិក ។

***លេខាធិការ***

- ត្រូវសហការជាមួយសមាជិកដើម្បីរៀបចំកម្មវិធីរបស់គណៈកម្មាធិការ និងរៀបចំរបៀបវារៈ និងសំណុំឯកសារពាក់ព័ន្ធសម្រាប់អង្គប្រជុំ
- ត្រូវសហការជាមួយសមាជិកដើម្បីរៀបចំប្រជុំបូកសរុបការងារ ឬសិក្ខាសាលា ដើម្បីតាមដាន និង វាយតម្លៃការអនុវត្តគម្រោង និងលើកទិសដៅសំរាប់អនុវត្តបន្ត
- រៀបចំកំណត់ហេតុ សេចក្តីជូនដំណឹង និង លិខិតរដ្ឋបាល ដាក់ជូនប្រធានចុះហត្ថលេខា ។

***សមាជិក***

- ផ្តល់របាយការណ៍សង្ខេបប្រចាំឆមាស និង ប្រចាំឆ្នាំស្តីអំពីការអនុវត្តការងាររបស់ក្រសួង-ស្ថាប័នរបស់ខ្លួនក្នុងក្របខ័ណ្ឌគម្រោងនេះ ដាក់ជូនលេខាធិការដ្ឋានអចិន្ត្រៃយ៍

- ស្វែងយល់អំពីផលប៉ះពាល់ជាយុទ្ធសាស្ត្រតាមរយៈលទ្ធផលរបស់គម្រោង
- ទទួលខុសត្រូវរៀបចំផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងគម្រោង និងធ្វើរបាយការណ៍ជូនស្ថាប័នរបស់ខ្លួន
- ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។
- សម្របសម្រួល និង ផ្តល់ជំនាញបច្ចេកទេសឱ្យដល់ភ្នាក់ងារអនុវត្តគម្រោងថ្នាក់ខេត្ត

**ប្រការ៣.-**

គណៈកម្មាធិការតម្រែតម្រង់ទិសនេះ ត្រូវរៀបចំប្រជុំសាមញ្ញយ៉ាងតិច០៦ខែម្តង និងប្រជុំវិសាមញ្ញតាមការចាំបាច់ ហើយត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលប្រជុំដាក់ជូនប្រមុខរាជរដ្ឋាភិបាល និង ម្ចាស់ជំនួយជ្រាប ។

**ប្រការ៤.-**

គណៈកម្មាធិការនេះត្រូវមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅក្នុងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្រោមការគ្រប់គ្រងរបស់លេខាធិការនៃគណៈកម្មាធិការ និងមានមន្ត្រីរបស់ក្រុមប្រឹក្សា-ស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មួយចំនួនជាជំនួយការតាមការចាំបាច់ ដោយជ្រើសរើសដោយប្រធានគណៈកម្មាធិការ ។

**ប្រការ៥.-**

គណៈកម្មាធិការនេះប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។

**ប្រការ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៧

ហ៊ុន សែន

***កន្លែងទទួល:***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ